**U.S. Department of Housing and Urban Development**
**Office of Housing    Office of Multifamily Housing Programs**

# ក្រដាសហេតុការណ៍

## សម្រាប់អ្នកស្នាក់នៅដែលបានជំនួយពី ក្រសួងអភិវឌ្ឍន៏លំនៅដ្ឋាននិងទីក្រុង

### ផ្នែក 202/162-កិច្ចសន្យា សម្រាប់ គំរោងជំនួយ ( Project Assistance Contract, PAC ) ផ្នែក 202/811-កិច្ចសន្យាសម្រាប់ គំរោងជំនួយក្នុងការជួល លំនៅដ្ឋាន ( Project Rental Assistance Contract, PRAC )

## តើថ្លៃជួលរបស់អ្នកត្រូវបានកំណត់ដូចម្តេចដែរ

### ការិយាល័យលំនៅដ្ឋាន

****ខែមិថុនា ឆ្នាំ 2007 ****

*ក្រដាសហេតុការណ៍នេះជាក្រដាសណែនាំទូទៅមួយក្នុងការផ្តល់ដំណឹងជូន ម្ចាស់ផ្ទះ/ភ្នាក់ងារចាត់ចែង ( Owner/Management Agents, OA ) និងអ្នកស្នាក់ នៅដែលបានជំនួយពី HUD អំពីការទទួលខុសត្រូវ និងសិទ្ធិ ដែលពាក់ព័ន្ធទៅនឹងការបង្ហាញប្រាក់ចំណូល និងការផ្ទៀងបញ្ជាក់។*

## ហេតុអ្វីបានជាការកំណត់នូវប្រាក់ចំណូល និងថ្លៃជួលឲ្យបានត្រឹមត្រូវ មានសារសំខាន់

ការសិក្សាស្រាវជ្រាវរបស់ក្រសួងអភិវឌ្ឍន៏លំនៅដ្ឋាន និងទីក្រុង ( Department of Housing and Urban Development, HUD ) បានបង្ហាញអោយឃើញថា គ្រួសារនៃអ្នក ស្នាក់នៅជាច្រើនបានចំណាយប្រាក់ទៅលើថ្លៃជួលមិនបានត្រឹមត្រូវ។ មូលហេតុចំបងនៃបញ្ហានេះគឺ:

- រាយការណ៏ប្រាក់ចំណូលរបស់ក្រុមគ្រួសារនៃអ្នកស្នាក់នៅតិចពេក និង
- OAs មិនទទួលស្គាល់ការបដិសេធន៏ និងកាត់ បន្ថយ ដែលក្រុមគ្រួសារនៃអ្នកស្នាក់នៅ មានសិទ្ធិទទួល។

OAs និងអ្នកស្នាក់នៅទាំងអស់គ្នាមានការទទួលខុស ដើម្បីឲ្យច្បាស់ថាថ្លៃជួលត្រូវបានបង់ត្រឹមត្រូវ។

### ការទទួលខុសត្រូវរបស់ភ្នាក់ងារចាត់ចែង( OA ):

- យកព័ត៌មានលើប្រាក់ចំណូលឲ្យបានត្រឹមត្រូវ
- ផ្ទៀងផ្ទាត់ប្រាក់ចំណូលរបស់អ្នកស្នាក់នៅ
- ធានាថាអ្នកស្នាក់នៅទទួលចំណូលដែលមិនរាប់និងការដកហូតផ្សេងៗ ដែលពួកគេមានសិទ្ធិទទួល
- គិតថ្លៃជួលផ្ទះឲ្យអ្នកជួលឲ្យបានត្រឹមត្រូវ
- ផ្តល់ជូនអ្នកជួលនូវច្បាប់ចម្លងនៃកិច្ចសន្យាជួលផ្ទះ ព្រមទាំងការកំណត់លើប្រាក់ចំណូល និងថ្លៃជួល។
- ពិនិត្យថ្លៃជួលឡើងវិញ ពេលមានការផ្លាស់ប្តូរ សមាជិកក្នុងគ្រួសារ និងនៅពេលប្រាក់ចំណូល ឡើងឬចុះលើស២០០ដុល្លារឡើងទៅ កុងមួយខែ
- ផ្តល់ជូនព័ត៌មានស្តីពីច្បាប់ទម្លាប់របស់ OA បើមានការស្នើសុំ
- ជូនដំណឹងដល់អ្នកជួលបើមានការផ្លាស់ប្តូរក្នុងសេចក្តីគំរូណាមួយ ឬផ្លាស់ ប្តូររបៀបរាយការណ៍លើ ប្រាក់ចំណូលឬរបៀបកំណត់ថ្លៃជួល

### ការទទួលខុសត្រូវរបស់អ្នកស្នាក់នៅ:

- ផ្តល់ព័ត៌មានពីសមាជិកគ្រួសារឲ្យបានច្បាស់លាស់
- រាយការណ៏ប្រាក់ចំណូលទាំងអស់
- រក្សាទុកច្បាប់ចម្លង ទម្រង់ពាក្យសុំ និងវិក័យប័ត្រ ដែលជាឯកសារប្រាក់ចំណូល និងការចំណាយ
- រាយការណ៏ពីការផ្លាស់ប្តូរសមាជិកគ្រួសារ និង ប្រាក់ចំណូលដែលបាននៅពេលការផ្ទៀងបញ្ជាក់
- ចុះហត្ថលេខានៅលើទម្រង់ពាក្យយល់ព្រមឲ្យគេផ្ទៀងផ្ទាត់ប្រាក់ចំណូល
- អនុវត្តតាមច្បាប់លំនៅដ្ឋានស្នាក់នៅ និងលក្ខខ័ណ្ឌក្នុងការជួល

## ការកំណត់លើប្រាក់ចំណូល

ប្រាក់ចំណូលស្មានទុកជាមុនសម្រាប់គ្រួសារមួយ នឹងកំណត់មិនត្រឹមតែភាពមានសិទ្ធិដើម្បីជំនួយនោះ ទេ តែថែមទាំងកំណត់នូវតម្លៃជួលដែលគ្រួសារនឹង បង់ព្រមទាំងប្រាក់ជំនួយពីរដ្ឋទៀតផង។ ប្រាក់ ចំណូលស្មានទុកជាមុនយកមកគិតគូរមានចំណូល ដែលមិនរាប់ខ្លះ និងដកចេញខ្លះ ដែលគ្រួសារនឹង ទទួលក្នុងកំឡុង១២ខែខាងមុខ នឹងយកមកប្រើ សម្រាប់កំណត់នូវថ្លៃជួលរបស់គ្រួសារ។

### តើអ្វីដែលគេហៅថាប្រាក់ចំណូលប្រចាំឆ្នាំ ?

ប្រាក់ចំណូលរកបាន – ចំណូលដែលមិនរាប់ = ប្រាក់ចំណូលប្រចាំឆ្នាំ

### តើអ្វីទៅដែលហៅថាប្រាក់ចំណូលទូទាត់ហើយ ?

ប្រាក់ចំណូលប្រចាំឆ្នាំ - ការដកចេញផ្សេងៗ = ប្រាក់ចំណូលទូទាត់ហើយ

# កំណត់ថ្លៃជួលទៅអ្នកជួល

ថ្លៃជួលដែលគ្រួសារនឹងត្រូវបង់ គឺចំនួនមួយណាដែល **ខ្ពស់ជាងគេបំផុត** ក្នុងចំណោមចំនួនប្រាក់ខាងក្រោម:

- 30 % នៃប្រាក់ចំណូល*ទូទាត់ហើយ*ប្រចាំខែរបស់គ្រួសារ
- 10 % នៃប្រាក់ចំណូលប្រចាំខែនៅក្នុងគ្រួសារ
- ឈ្នួលបានពីក្រសួងសុខមាលភាព ( Welfare ) ឬប្រាក់បង់ឲ្យពីក្រសួងសុខមាលភាពដោយភ្នាក់ងារ ដើម្បីជួយដល់ក្រុមគ្រួសារក្នុងការបង់ថ្លៃ ឈ្នួលលំនៅដ្ឋាន។

**សេចក្តីកត់សំគាល់:** ម្ចាស់លំនៅដ្ឋានអាចអនុញ្ញាតអោយអ្នកដាក់ពាក្យសុំចូលទៅក្នុងកម្មវិធី PAC តែក្នុងករណីប្រាក់ចំណាយ សរុបរបស់អ្នកជួល ( Total Tenant Payment )តិចជាងតម្លៃ ជួលដើម។
សេចក្តីកត់សំគាល់នេះមិនអនុវត្តទៅលើកម្មវិធី PRACទេ។ ក្នុងករណីខ្លះ នៅក្រោមកម្មវិធី PRAC ប្រាក់ចំណាយសរុបរបស់អ្នកជួល ( Total Tenant Payment ) នឹងលើសពីតម្លៃជួលក្នុងការគ្រប់គ្រងរបស់ PRAC ( តម្លៃជួលដើម មិនទាន់ជាត់ Gross Rent )

# ប្រាក់ចំណូល និងទ្រព្យធន

ប្រជាជនដែលជួយដោយក្រសួងHUD ត្រូវតំរូវឲ្យរាយការណ៍ប្រាក់ចំណូល**ទាំងអស់** ដែលបានមកពីប្រភពផ្សេងៗទៅម្ចាស់លំនៅដ្ឋាន ឬភ្នាក់ងារ ( OA ) ប្រាក់មិនរាប់ចូលក្នុងប្រាក់ចំណូល និងប្រាក់ ដកចេញផ្សេងៗ ជាកត្តាមួយផ្នែកនៅពេលជួល។

នៅពេលកំណត់ចំនួនប្រាក់ចំណូលពីទ្រព្យធន ដើម្បីបញ្ចូលក្នុងប្រាក់ចំណូលប្រចាំឆ្នាំ ប្រាក់ចំណូលពិតៗ ដែលបានមកពីទ្រព្យធនគឺបានបូកបញ្ចូល ហើយ លើកលែងនៅពេលតម្លៃជាប្រាក់សុទ្ធនៃទ្រព្យធនទាំងអស់ច្រើនជាង៥០០០ដុល្លារ នោះចំនួនប្រាក់ដែលរាប់ បញ្ចូលក្នុងប្រាក់ចំណូលប្រចាំឆ្នាំផងនោះនឹងច្រើនជាង ២% នៃទ្រព្យសរុបទាំងអស់ ឬប្រាក់ចំណូលពិតៗ ដែលបានមកពីទ្រព្យធន

## ប្រាក់ចំណូលប្រចាំឆ្នាំរួមមាន:

- ចំនួនប្រាក់ចំណូលពេញ ( មុនពេលកាត់បន្ថយ ចំណាយខ្លះពីបញ្ជីប្រាក់ខែ ) នៃប្រាក់ឈ្នួលនិង ប្រាក់ខែ ប្រាក់ធ្វើការលើសម៉ោង ប្រាក់លើកទិក ចិត្ត ប្រាក់ធីប និងប្រាក់រង្វាន់ និងប្រាក់ទូទាត់ផ្សេងទៀតសម្រាប់សេវាកម្មផ្ទាល់
- ប្រាក់ចំណូលចុងក្រោយបានមកពីការរកស៊ី ឬប្រកបរបរណាមួយ
- ប្រាក់ការ ប្រាក់ចំណេញ និងប្រាក់ចំណូល នៃទ្រព្យសម្បត្តិផ្ទាល់ ឬទ្រព្យសម្បត្តិជាផ្ទះ ( សូមមើលទ្រព្យធន រាប់បញ្ចូល /ទ្រព្យធន កុំរាប់បញ្ចូលខាងក្រោម )
- ប្រាក់ចំណូលពេញបានម្តងម្កាលពីប្រាក់សន្តិសុខសង្គម ( Social Security ) ប្រាក់បង់ប្រចាំឆ្នាំ ប្រាក់ពីក្រុមហ៊ុន ធានារ៉ាប់រង ប្រាក់ចូលនិវត្តន៍ ប្រាក់សោធននិវត្តន៍ ប្រាក់បានពីមរណភាព ឬ ប្រាក់ជនពិការ និង ប្រភេទប្រាក់ចំណូលមើល តាមបង្កាន់ដៃ រួមមាន ចំនួនប្រាក់ទទួលសរុបតែម្តង ឬចំនួនប្រាក់ប្រចាំខែ ដែលរំពឹងនឹងបានមក ពី ការចាប់ផ្តើមយឺត **( លើកលែងតែ ប្រាក់បាន តាមកាលកំណត់ម្តងៗមកពីក្រសួងសង្គមកិច្ច និងប្រាក់កំរៃសុវត្ថិ ភាពសង្គម ( សូមមើលប្រាក់មិនរាប់ចូលមកពីចំណូលប្រចាំឆ្នាំ ខាងក្រោម ) **
- ប្រាក់បានដោយមិនបានធ្វើការ ដូចជាប្រាក់ពេលគ្មានការងារធ្វើ ប្រាក់ទូទាត់ពេលធ្វើការ មិនកើត ប្រាក់ទូទាត់របស់កម្មករ និងការចំណាយទៅលើការចែកផ្លូវគ្នា **( លើកលែងប្រាក់សរុប បន្ថែមទៅលើទ្រព្យធន សូមមើលប្រាក់មិនរាប់ ចូលមកពីចំណូលប្រចាំឆ្នាំ ខាងក្រោម ) **
- ប្រាក់ជំនួយខាងផ្នែកសុខមាលាភាព
- ប្រាក់ឧបត្ថម្ភដែលបានកំណត់ និងតាមកាល កំណត់ ដូចជាការចំណាយទៅលើកូនក្នុងបន្ទុក និងប្តី ឬប្រពន្ធក្រោយពេលលែងលះ និងប្រាក់បានពីការបរិចាគទៀងទាត់ ជាអំណោយ ពីអង្គការណាមួយ ឬពីនរណាម្នាក់ដែលមិនបាន ស្នាក់នៅក្នុងលំនៅដ្ឋាន
- ប្រាក់ទៀងទាត់ទាំងអស់ ប្រាក់ពិសេសចំណាយ ដែលឧបត្ថម្ភដល់សមាជិកទាហ៊ាន ( លើកលែង តែប្រាក់បង់លើទាហ៊ានណាស្លាប់ដោយសារ កាំភ្លើងមិត្តភាព
- **សម្រាប់កម្មវិធីនៃផ្នែកលេខ៨ ប៉ុណ្ណោះ លុយ ជំនួយឧបត្ថម្ភបង់ថ្លៃសាលាណាដែលសល់ ទទួលលើសពីចំនួនដែលកំរិតឲ្យ យោងតាម ច្បាប់អប់រំកំរិតខ្ពស់នៃឆ្នាំ១៩៦៥ ត្រូវចាត់ទុកជា ប្រាក់ចំណូលសម្រាប់បុគ្គលនោះ លើកលែងតែ ជំនួយហិរញ្ញវត្ថុន មិនបានចាត់ទុកជាប្រាក់ចំណូលប្រចាំឆ្នាំសម្រាប់អ្នកនោះដែលមានអាយុ២៣ឆ្នាំនឹងមានកូនក្នុងបន្ទុក ឬប្រសិនជានិស្សិតកំពុងរស់នៅ ជាមួយឪពុកម្តាយ ដែលកំពុងទទួលបានជំនួយ នៃផ្នែកលេខ៨។ សម្រាប់គោលបំណងនៃវគ្គនេះ "ជំនួយហិរញ្ញវត្ថុ" មិនរាប់បញ្ចូលនូវប្រាក់ខ្ចីបាន មកក្នុងគោលបំណងកំណត់ប្រាក់ចំណូលទេ **

## ទ្រព្យធនរួមមាន:

- ស្តុកបនដើមទុន ប្រាក់ធានា ប័ណ្ណរតនាគា វិញ្ញាបនប័ត្រនៃការកក់ ខ្ទង់គណនី
- គណនីលុយចូលនិវត្តន៍ម្នាក់ៗ និងគណនី Keogh
- ប្រាក់ឧបត្ថម្ភពេលចូលនិវត្ត និងប្រាក់ឧបត្ថម្ភសោធន
- គណនីប្រាក់សន្សំ ប្រាក់សុទ្ធនៅប្រអប់ប្រាក់ផ្ញើរ ទុកនៅធនាគារ លំនៅដ្ឋាន

- តម្លៃជាប្រាក់សុទ្ធទិញសំរាប់ធានារ៉ាប់រងជីវិតងមូល ដែលអាចផ្តល់ទៅអោយបុគ្គលមុនពេល ទទួលមរណភាព
- តម្លៃជាប្រាក់នៃទ្រព្យសម្បត្តិដែលមានជួល និងការវិនិយោគទុនផ្សេងទៀត
- ទ្រព្យសម្បត្តិផ្ទាល់ដែលចាត់ទុកជាវិនិយោគទុន
- លុយទទួលសរុប រឺ លុយទទួលតែម្តង
- ការបញ្ចាំ ឬលិខិតដីធ្លីដែលអ្នកដាក់ពាក្យសុំមាន
- ទ្រព្យធនណាទុកថាទាបជាងតម្លៃត្រឹមត្រូវលើទីផ្សា

## ទ្រព្យធនមិនរាប់បញ្ចូល:

- ទ្រព្យសម្បត្តិចាំបាច់របស់ម្នាក់ៗ (សំលៀកបំពាក់ គ្រឿងសង្ហារឹម រថយន្ត ចិញ្ចៀនអាពាហ៍ពិពាហ៍ រទេះពិសេសសម្រាប់បុគ្គលពិការ)
- ការប្រាក់ដីធ្លីនៃជនជាតិកំណើតឥណ្ឌាដើម
- ការកំណត់គោលច្បាប់ការ ធានារ៉ាប់រងជីវិត
- តម្លៃជាប្រាក់នៃផ្ទះនៅរួមដែលជាកន្លែងដែល គ្រួសារស្នាក់នៅ
- ទ្រព្យធនដែលជាផ្នែកមួយនៃជំនួញកំពុងដើរ
- ទ្រព្យធនដែលមិនមែនជាកម្មសិទ្ធិរបស់អ្នកដាក់ ពាក្យសុំ ឬដាក់ក្នុងឈ្មោះបុគ្គលណាម្នាក់ ប៉ុន្តែ:
  - ទ្រព្យធន និងប្រាក់ចំណូលណាខ្លះដែលពួក គេទទួលតៗពីអ្នកណាម្នាក់ទៀត ដែលមិនមែន ជាសមាជិកនៅក្នុងគ្រួសារ និង
  - អ្នកផ្សេងនោះជាអ្នកទទួលខុសត្រូវទៅចំពោះ ពន្ធដារលើប្រាក់ចំណូលដែលកើតមកពីទ្រព្យធនទាំងនោះ
- ទ្រព្យធនណាអ្នកដាក់ពាក្យសុំគ្មានសិទ្ធិទទួល យកហើយទ្រព្យមិនបង្កើតជាប្រាក់ចំណូលដល់ អ្នកដាក់ពាក្យសុំឡើយ (ឧទាហរណ៍: ប្រពន្ធដែលបែកបាក់ពីគ្រួសារមានផ្ទះរួមជាមួយប្តី។ ដោយសារស្ថានភាពទាស់ទែងគ្នា ប្រពន្ធមិន រាប់ថាអាចទទួលប្រាក់ចំណូលពីទ្រព្យធនទេ និង មិនអាចប្តូរទ្រព្យធននោះទៅជាប្រាក់សុទ្ធឡើយ។)
- ទ្រព្យធនដែលទុកថាមានតម្លៃតិចជាងតម្លៃទីផ្សារដោយសារ:
  - ប្តឹងរឹបអូស
  - ខ្សុំយទុន
  - ការលែងលះ ឬយល់ព្រមរស់នៅបែកគ្នា បើអ្នក ដាក់ពាក្យសុំ ឬអ្នកស្នាក់នៅបាន ទទួលអ្វីសំ ខាន់ខ្លះតែមិនចាំបាច់គិតជាដុល្លារទេ។

## ប្រាក់មិនរាប់ចូលក្នុងប្រាក់ចំណូលប្រចាំឆ្នាំ:

- ប្រាក់ចំណូលបានមកពីឲ្យក្មេងក្រោមអាយុ១៨ឆ្នាំ ធ្វើការ (រាប់ទាំងកូនចិញ្ចឹម)
- ប្រាក់ទទួលបានពីការថែទាំក្មេងកូនចិញ្ចឹម ឬកូនចិញ្ចឹមពេញវ័យ (តាមធម្មតាមនុស្សពិការ គ្មានទំនាក់ទំនងជាមួយគ្រួសារអ្នកជួលលំនៅដ្ឋាន ហើយជាអ្នកមិនអាចរស់នៅតែម្នាក់ឯង)
- ប្រាក់ចំណូលសរុបបន្ថែមពីលើទ្រព្យធននៅក្នុងគ្រួសារ ដូចជាកេរ្តិ៍មរតក ប្រាក់ក្រុមហ៊ុនធានារ៉ាប់រង ចំណាយឲ្យ (មានការបង់ថ្លៃលើសុខភាព និងការរងគ្រោះថ្នាក់ និងប្រាក់ទូទាត់កម្មករឈឺ) ប្រាក់បានពិសេស ប្រាក់បានពីការទូទាត់ការខូចខាតលើទ្រព្យសម្បត្តិឬផ្ទាល់ខ្លួន
- ប្រាក់ដែលគ្រួសារទទួលក្នុងថ្លៃចំណាយលើថ្នាំ ពេទ្យរួមទាំងសមាជិកគ្រួសារផង
- ប្រាក់ចំណូលរបស់អ្នកបំរើ
- * *អាចនឹងរាប់បញ្ចូលនូវប្រាក់ចំណូលសម្រាប់កម្មវិធីផ្នែកទី៨ ចំពោះនិស្សិតដែលចុះឈ្មោះរៀននៅ ក្នុងស្ថាប័នអប់រំកំរិតខ្ពស់ ដោយយកប្រាក់ ចំណូលប្រចាំឆ្នាំ ខាងលើមកប្រើ។
  * *ចំនួនប្រាក់ទាំងអស់នៃជំនួយហិរញ្ញវត្ថុរបស់ និស្សិតទោះបង់ផ្ទាល់ទៅអោយនិស្សិត ឬបង់ទៅ ស្ថាប័នសិក្សាក៏ដោយ
- ប្រាក់បង់ពិសេសឲ្យទៅសមាជិកគ្រួសារទាហ៊ាន ដែលមានគ្រោះថ្នាក់ដោយសារអាវុធសត្រូវ
- ចំនួនប្រាក់ដែលទទួលពីកម្មវិធីហ្វឹកហ្វឺន ដែលផ្តល់ ជូនដោយ HUD
- ប្រាក់ទទួលដោយបុគ្គលពិការដែលមិនបានគិតគូរក្នុងមួយរយ: ទុកជាប្រាក់សន្តិសុខបន្ថែមអាចមានសិទ្ធិទទួល បានតាមក្រសួងសង្គមកិច្ច ព្រោះប្រាក់នោះត្រូវបានទុក មួយកន្លែងសម្រាប់ប្រើ តាមផែនការដើម្បីអាចទ្រទ្រង់ ខ្លួនឯងបាន (Plan to Attain Self-Sufficiency, PASS)
- ប្រាក់ទទួលដោយអ្នកចូលរួមនៅក្នុងកម្មវិធីជំនួយសាធារណ:ណាមួយ ដែលត្រូវឲ្យបង់ផ្ទាល់ឬសងការចំណាយលុយហោប៉ៅផ្ទាល់ខ្លួន (គ្រឿងបរិក្ខារពិសេស សំលៀកបំពាក់ ការធ្វើដំណើរ ការថែទាំក្មេង ។ល។) ហើយកម្មវិធីនោះត្រូវបានធ្វើឡើងដើម្បីអនុញ្ញាត ឲ្យចូលរួមនៅក្នុងកម្មវិធីពិសេប៉ុណ្ណោះ
- ថ្លៃឈ្នួលសេវាកម្មស្នាក់នៅ (មិនលើសពី ២០០ដុល្លារក្នុងមួយខែ)
- ប្រាក់កម្រៃកើនបន្តិចម្តងៗដល់សមាជិកគ្រួសារណាដែលមានសិទ្ធិចូលរួម នៅក្នុង កម្មវិធីហ្វឹកហ្វឺនរបស់រដ្ឋឬស្រុក និងការបណ្តុះប ណ្តាលសមាជិកគ្រួសារជាបុគ្គលិកគ្រប់គ្រង
- ប្រាក់ចំណូលបានមកមិនទៀង យូរៗម្តងឬ បណ្តោះអាសន្ន (រាប់បញ្ចូលទាំងអំណោយផងដែរ)
- ប្រាក់សងដោយរដ្ឋាភិបាលបរទេស យោងតាមពាក្យបណ្តឹងតាមច្បាប់ប្រទេសនោះ ពីប្រជាជនដែលដែលត្រូវបានទទួលរងការធ្វើទុកបុកម្នេញក្នុងសម័យណាហ្ស៊ី
- ប្រាក់ចំណូលរកបានលើសពី៤៨០ដុល្លារ សម្រាប់និស្សិតអាយុ១៨ឆ្នាំ ឡើងទៅ (មិនរាប់មេគ្រួសារ សហមេគ្រួសារ ឬប្រពន្ធទេ)
- ប្រាក់បានមកពីការជួយសំរួលរឿងរ៉ាវការយកកូនចិញ្ចឹម លើសពី៤៨០ដុល្លារទៅ ក្នុងកូនចិញ្ចឹមម្នាក់
- ប្រាក់បានមកម្តងម្កាលពីក្រសួងសង្គមកិច្ចជាចំនួនសារុបឬប្រចាំខែ

- ប្រាក់ដែលគ្រួសារទទួលជាជាការសន្យាក្នុងការ ផ្សាយ ឬប្រាក់បង្វិលមកអោយវិញដោយអនុលោម ទៅតាមច្បាប់ក្នុងស្រុករបស់រដ្ឋ
- ប្រាក់បង់ដោយភ្នាក់ងាររដ្ឋទៅអោយគ្រួសារដែលមានសមាជិកជាអ្នកពិការផ្លូវរីកចំរើនហើយរស់នៅ ក្នុងផ្ទះជាមួយ ដើម្បីបន្ថយបន្ថយនូវថ្លៃសេវាកម្ម និងសម្ភារៈដែលចាំបាច់ប្រើប្រាស់សម្រាប់សមាជិកពិការនោះ

## ប្រាក់មិនរាប់ចូលតំរូវពីសហព័ន្ធ:

- តម្លៃដីជួលផ្តល់ជូនទៅអោយគ្រួសារដែលមានសិទ្ធិទទួលបាន តាមបញ្ញត្តិប័ណ្ណអាហារ នៃឆ្នាំ១៩៧៧ ( Food Stamp Act of 1977 )
- ប្រាក់បង់ទៅអោយអ្នកស្ម័គ្រចិត្តយោងតាម បញ្ញត្តិសេវាកម្មស្ម័គ្រចិត្តក្នុងស្រុកនៃឆ្នាំ១៩៧៣ ( Domestic Volunteer Services Act of 1973 )
  - ប្រាក់ទទួលតាមបញ្ញត្តិសម្រាប់អ្នកមានដើមកំណើតនៅអាឡាស្កា ច្បាប់នៃការតាំងភូមិលំនៅ ( Alaska Native Claims Settlement Act. )
- ប្រាក់ចំណូលដែលបានមកពីតំបន់ដីធ្លីណាមួយនៃសហរដ្ឋអាមេរិក ដែលទុកជាតំបន់នៃកុលសម្ព័ន មានដើមកំណើតឥណ្ឌា ( Indian Tribes )
- ប្រាក់ចំណាយ ឬប្រាក់ឧបត្ថម្ភបានតាមកម្មវិធី ជំនួយហាមពលរបស់ក្រសួងសុខាភិបាលនិង សេវាកម្មមនុស្សដល់គ្រួសារដែលរកប្រាក់ ចំណូលបានទាប
- ប្រាក់ចំណាយបានតាមកម្មវិធីដែលផ្តល់ប្រាក់ទាំង ស្រុង ឬដោយផ្នែកៗយោងតាមច្បាប់ពួតដៃហ្វឹក ហ្វឹនការងារ
- ប្រាក់ចំណូលបានមកពីមូលនិធិទូទាត់អោយទៅ ក្រុម Grand River Band of Ottawa Indians.
- ចំនួនប្រាក់២០០០ដុល្លារដំបូងសម្រាប់មនុស្សម្នាក់បានមកពីមូលនិធិសាលក្រម ដែលផ្តល់រង្វាន់ជូន ដោយគណៈកម្មការទាមទារនៃជនជាតិមានដើមកំណើតឥណ្ឌា ឬតាមតុលាការដោះស្រាយការ តវ៉ានៃសហរដ្ឋអាមេរិក ( Indian Claims Commission or the US Claims Court ), ការប្រាក់បានមកពីមូលនិធិ របស់ជនជាតិកំណើតឥណ្ឌាម្នាក់ៗ ឬមកពីដីមានព្រំដែនកំណត់ ដោយរួមបញ្ចូលចំនួនប្រាក់ 2000 ដុល្លារក្នុង1ឆ្នាំនៃប្រាក់ចំណូលដែលទទួល ដោយជនជាតិកំណើតឥណ្ឌាម្នាក់ៗពីមូលនិធិ ដែលបានមកពីការប្រាក់តំកល់ទុកក្នុងកុងឬមកពី លើដីដែលមានព្រំដែនកំណត់
- ចំនួនអាហារូបករណ៍តំកល់ទុកតាមមាត្រាទី៤ នៃបញ្ញត្តិអប់រំជាន់ខ្ពស់នៃឆ្នាំ១៩៦៥( Title IV of the Higher Education Act of 1965 ) ដែលរាប់ទាំងរង្វាន់ ក្រោមកម្មវិធីធ្វើការរៀនរបស់សហព័ន្ធឬក្រោមកម្មវិធីជួយនៃការិយាល័យកិច្ចការជនជាតិដើមកំណើតឥណ្ឌា ( Bureau of Indian Affairs )
- ប្រាក់ទទួលពីកម្មវិធីដែលផ្តល់តាមបញ្ញត្តិ Title V of the Older Americans Act of 1985
- ប្រាក់ទទួលនៅថ្ងៃឬក្រោយថ្ងៃទី១ខែមករា ១៩៨៩ ពីមូលនិធិ Agent Orange Settlement Fund ឬពីមូលនិធិដទៃទៀតបង្កើតឡើងយោងតាមការដោះស្រាយក្នុងពាក្យបណ្តឹង In Re Agent-product
- ប្រាក់ទទួលតាមរយៈច្បាប់បញ្ញត្តិ Maine Indian Claims Settlement Act of 1980
- តម្លៃនៃការថែទាំកុមារបានផ្តល់ជូន ឬរៀបចំជូន (ឬចំនួនណាដែលទទួលបានជាប្រាក់ចំណាយសម្រាប់ការថែទាំទាំងនោះឬការទូទាត់តម្លៃដែលត្រូវបង់សម្រាប់ការថែទាំទាំងនោះ ) យោងតាមច្បាប់ Child Care and Development Block Grant Act of 1990
- ឥណទានពន្ធប្រាក់ចំណូលដែលរកបាន ( EITC ) ប្រាក់ដែលទទួលនៅថ្ងៃឬក្រោយថ្ងៃទី១ មករា ១៩៩១
- ប្រាក់បានពីគណៈកម្មការតវ៉ានៃជនជាតិដើមឥណ្ឌា Indian Claims Commission ទៅអោយកុលសម្ព័ន្ធសហព័ន្ធនិងក្រុមជនជាតិដែលមានកំណើតយ៉ាគីម៉ាឥណ្ឌា Confederated Tribes and Bands of Yakima Indian Nation ឬក្រុមអភិរក្សកុលសម្ព័ន្ធ Apache Tribe of Mescalero Reservation.
- ប្រាក់ឧបត្ថម្ភ ប្រាក់រកបាន និងប្រាក់បង់ទៅអោយ អ្នកចូលរួមធ្វើជាប៉ូលីសអាមេរិកាំង( AmeriCorps )តាមរយៈបញ្ញត្តិសេវាកម្មជាតិនិងសហគមន៍ នៃឆ្នាំ១៩៩០
- ប្រាក់ឧបត្ថម្ភណាចំណាយក្រោមច្បាប់38U.S.C 1805 ទៅក្មេងដែលទទួលរងគ្រោះដោយសារឈឺពិការឆ្អឹងខ្នងហើយកូននោះជាកូនរបស់អតីតយុទ្ធជនចូលរួមក្នុងសង្គ្រាមនៅវៀតណាម
- ប្រាក់ណាជាសំណងនៃបទឧក្រិដ្ឋ ( តាមបញ្ញត្តិ Victims of Crime Act ) ទទួលតាមរយៈជំនួយដល់ជនរងគ្រោះដោយបទឧក្រិដ្ឋ ( ជាប្រាក់បង់អោយ ឬប្រាក់សងលើថ្លៃរត់ជំ នួយការ )ដូចបានកំណត់ដោយបញ្ញត្តិVictims of Crime Act ដោយសារគណកម្មការនៃបទឧក្រិដ្ឋ ចំពោះអ្នកសុំពាក្យតាមបញ្ញត្តិVictims of Crime Act
- ប្រាក់ឧបត្ថម្ភ ប្រាក់រកបាន និងប្រាក់ចំណាយលើ បុគ្គលណាដែលចូលរួម ក្រោមបញ្ញត្តិវិនិយោគ កំលាំងការងារ នៃឆ្នាំ១៩៩៨ ( Workforce Investment Act of 1998 ) ប្រាក់កម្រៃពន្យាសំរាប់ពិការភាពណា ពីក្រសួងកិច្ចការអតីតយុទ្ធជន ( Department of Veterans Affairs ) ដែលបានទទួលជាចំនួនសរុប ឬចំនួនស្មានជា ប្រចាំខែ ទៅអ្នកជួលលំនៅដ្ឋាន
- ឲ្យ គោរពតាម បញ្ញត្តិ Housing and Economic Recovery Act of 2008 ( HERA ).

## ការដកចេញផ្សេងៗ:

- ប្រាក់ 480ដុល្លារសម្រាប់អ្នកនៅក្នុងបន្ទុកម្នាក់ៗ ដូចជានិស្សិតទៅរៀនពេញម៉ោង ឬអ្នកពិការ
- ប្រាក់400ដុល្លារសម្រាប់គ្រួសារជរានិងពិការ
- ប្រាក់ដែលមិនបានសងដល់ការចំណាយលើពេទ្យនៃគ្រួសារមនុស្សជរាឬពិការ ដែលមានចំនួន លើសពី៣%នៃប្រាក់ចំណូលប្រចាំឆ្នាំឡើងទៅ
- ប្រាក់ដែលមិនបានសងចំណាយលើអ្នកថែទាំសមរម្យ និងលើប្រដាប់ប្រដារជំនួយដល់សមាជិកពិការ ដើម្បីឲ្យសមាជិកគ្រួសារនោះអាចទៅធ្វើការបាន ដែលលើសពី៣%នៃប្រាក់ចំណូលប្រចាំឆ្នាំ ឡើងទៅ
- បើគ្រួសារមានមនុស្សចាស់ជរាមានការចំណាយទៅលើពេទ្យ និងជំនួយការថែទាំក្នុងពិការភាពសរុបគ្នា មិនបានសង ការចំណាយចំនួន៣%នៃប្រាក់ ចំណូលគ្រួសារនឹងយកមកគិតគូរពេលម្តង
- ប្រាក់ចំណាយណាលើការថែទាំក្មេងដែលអាយុនៅក្រោម១៣ឆ្នាំ ដើម្បីឲ្យសមាជិកគ្រួសារអាចទៅ ធ្វើការ ឬទៅបន្តការសិក្សាបាន។

## ឯកសារយោង

បទបញ្ជា:

- សេចក្តីតំរូវលើកម្មវិធីទូទៅនៃក្រសួង HUD; 24 CFR ផ្នែកទី 5 និង CFR 24 ផ្នែកទី 891 ( General HUD Program Requirements; 24 CFR Part 5 and CFR 24 Part 891 )

សៀវភៅដៃ:

- 4350.3, Occupancy Requirements of Subsidized Multifamily Housing Programs

សេចក្តីប្រកាស:

- Federally Mandated Exclusions ប្រកាសលេខ 66 FR 4669, ថ្ងៃទី20 ខែមេសា ឆ្នាំ 2001

សម្រាប់ព័ត៌មានបន្ថែម:
សូមធ្វើការស្វែងយល់បន្ថែមអំពីកម្មវិធីរបស់ HUD
នៅលើគេហទំព័រអ៊ីនធឺណេតតាមអាស័យដ្ឋាន http://www.hud.gov